**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ០១៣/២០០៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៣

**ជំរាបមក**

**លោក ឡេង សេង ប្រធានគណបក្សកសាងជាតិ**

**កម្មវត្ថុ** : អំពីបណ្តឹងតវ៉ាលើសេចក្តីប្រកាសបដិសេធការចុះបញ្ជីគណបក្សកសាងជាតិ ឈរឈ្មោះបោះឆ្នោត

**យោង** : - សេចក្តីសំរេចរបស់ គ.ជ.ប លេខ ០៥.៧៩៧.០៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៣

- ពាក្យបណ្តឹងលេខ ០២៩.០៣ គកជ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣ របស់គណបក្សកសាងជាតិ

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចអនុគ្រោះតាមសំណូមពររបស់លោកបានទេ ពីព្រោះការដែលមិនបានបំពេញបន្ថែមល័ក្ខខ័ណ្ឌទី១០ នៃមាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនោះ ឱ្យទាន់ក្នុងរយៈពេលកំណត់ដោយច្បាប់ត្រូវចាត់ទុកថាគណបក្សលោកបានបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដូចមានចែងក្នុងវាក្យខ័ណ្ឌចុងក្រោយនៃ មាត្រា ៤០ថ្មី នៃព្រះរាជក្រម នស.រកម.០៩០២.០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រហើយ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**